# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខៈ ៦៧ សសរ

## សេចក្តីសំរេច

## ស្តីពី

## ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

★ ★ ★ ★

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៣/២០២ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការតែងតាំង ឯកឧត្តម ឃុន ជិនកេន ជាអគ្គលេខាធិការរង រាជរដ្ឋាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ
- យោងតាមសេចក្តីត្រូវការចាំបាច់របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សំរេច

**ប្រការ១.-** ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម **ឃុន ជិនកេន** អគ្គលេខាធិការរងរាជរដ្ឋាភិបាល អោយទទួលបន្ទុក ការងាររដ្ឋបាល បុគ្គលិក និងពិធីការ នៃទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ២.-** ឯកឧត្តមអគ្គលេខាធិការរាជរដ្ឋាភិបាល លោកប្រធាននាយកដ្ឋានបុគ្គលិក នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានពិធីការ នាយកដ្ឋានផ្គត់ផ្គង់និងហិរញ្ញកិច្ច គ្រប់នាយកដ្ឋានពាក់ព័ន្ធ និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ០៦ ឆ្នាំ២០០៣

ទេសរដ្ឋមន្ត្រី

សុខ អាន

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ២
- ឯកសារ-កាលប្បវត្តិ